01465661

**Declassified to Public**
**28 June 2019**

លេខ៖ D354

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

ការិយាល័យសហចៅក្រមស៊ើបអង្កេត
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 04 / 05 / 2017
ម៉ោង (Time/Heure): 11:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

សំណុំរឿងលេខ៖ ០០៤/០៧-០៩-២០០៩-ស.ស.ច.ស -ក.ស.ច.ស

| | |
|---|---|
| ចំពោះមុខ ៖ | សហចៅក្រមស៊ើបអង្កេត |
| កាលបរិច្ឆេទ ៖ | ថ្ងៃទី០៤ ខែឧសភា ឆ្នាំ ២០១៧ |
| ភាសា ៖ | ខ្មែរ/អង់គ្លេស [ភាសាដើម] |
| ចំណាត់ថ្នាក់ឯកសារ ៖ | សម្ងាត់ |

# សេចក្តីជូនដំណឹងយោងតាមវិធានផ្ទៃក្នុង ៦៦ស្ទួន (២)

**ផ្ញើជូន៖**

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**មេធាវីការពារក្តី យឹម ទិត្យ**
សូ មូស្សេនី
Suzana TOMANOVIĆ

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
ជេត វណ្ណលី
ហុង គីមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន ស៊ីវ៉ន
ទី ស្រីនណា
វ៉ែន ពៅ
Laure DESFORGES
Isabelle DURAND
Emmanuel JACOMY
Martine JACQUIN
Lyma NGUYEN
Nushin SARKARTI

## I. ប្រវត្តិនីតិវិធី

១. ករណីខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត ("ស.ច.ស") នៅក្នុងសំណុំរឿងនេះ បានចុះបញ្ជីនៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣ ថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១៣ ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៥ និងថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៧។

២. នៅថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០១៦ នៅក្នុងសំណើសុំមតិយោបល់ទាក់ទងនឹងការចោទប្រកាន់អំពីអង្គហេតុដែលនឹងមិនស៊ើបអង្កេតថែមទៀតទេ[1] ខ្ញុំបានជូនដំណឹងភាគីទាំងអស់អំពីបំណងរបស់ខ្ញុំមិនស៊ើបអង្កេតថែមទៀតលើអង្គហេតុមួយចំនួន។

៣. យឹម ទិត្យ បានដាក់មតិយោបល់នៅថ្ងៃទី ៨ ខែ មេសា ឆ្នាំ ២០១៦[2] ហើយសហព្រះរាជអាជ្ញាអន្តរជាតិ ("ស.ព.អ") បានដាក់មតិយោបល់នៅថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៦[3]។

៤. នៅថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦ ខ្ញុំបានចេញសេចក្តីជូនដំណឹងអំពីការផ្អាកកិច្ចស៊ើបសួរទាក់ទងនឹងការចោទប្រកាន់នីមួយៗ[4] ដែលក្នុងនេះ ខ្ញុំបានជូនដំណឹងភាគីទាំងអស់ថា ខ្ញុំនឹងមិនស៊ើបអង្កេតថែមទៀតលើអង្គហេតុដូចខាងក្រោម ដែលបានចោទនៅក្នុងដីកាសន្និដ្ឋានរបស់ ស.ព.អ ដែលជាបឋមបង្ហាញឱ្យឃើញថាអាចអនុវត្តវិធានផ្ទៃក្នុង ៦៦ *ស្ទួន*៖

ក) **អង្គហេតុទី៦**- ការចោទប្រកាន់ទាំងអស់ទាក់ទងនឹងទីតាំងសម្លាប់មនុស្សដំណាក់វាំង[5]។

---

[1] សំណុំរឿង ០០៤ ឯកសារ D302 *សំណើសុំមតិយោបល់ទាក់ទងនឹងការចោទប្រកាន់អំពីអង្គហេតុដែលនឹងមិនស៊ើបអង្កេតថែមទៀតទេ* ថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០១៦។

[2] សំណុំរឿង ០០៤ ឯកសារ D302/1 *សារណារបស់ យឹម ទិត្យ ទាក់ទងនឹងការចោទប្រកាន់អំពីអង្គហេតុដែលនឹងមិនស៊ើបអង្កេតបន្ថែមទៀត* ថ្ងៃទី ៨ ខែ មេសា ឆ្នាំ ២០១៦។

[3] សំណុំរឿង ០០៤ ឯកសារ D307/2 *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិសុំមតិយោបល់ទាក់ទងនឹងការចោទប្រកាន់អំពីអង្គហេតុដែលមិនស៊ើបអង្កេតបន្ថែម* ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៦។

[4] សំណុំរឿង ០០៤ ឯកសារ D307/3 *សេចក្តីជូនដំណឹងអំពីការផ្អាកកិច្ចស៊ើបសួរទាក់ទងនឹងការចោទប្រកាន់នីមួយៗ* ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦។

[5] សំណុំរឿង ០០៤ ឯកសារ D65 *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់ ១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម* ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១១ កថាខណ្ឌ ៩ ("ដីកាសន្និដ្ឋានបន្ថែមទី ១")។

ខ) **អង្គហេតុទី ១៣-** ការចោទប្រកាន់អំពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅជិតទំនប់កង្ហត[6]។

គ) **អង្គហេតុទី ១៤-** ការចោទប្រកាន់ទាក់ទងនឹងទីតាំងនៅតំបន់ ៥ ភូមិភាគពាយ័ព្យ៖

- មន្ទីរសន្តិសុខ និងការដ្ឋានភ្នំទ្រយោង[7]
- ការដ្ឋានស្ពានស្រែង និងការដ្ឋានទំនប់ព្រៃរនាម[8]
- វត្តព្រះនេត្រព្រះ និងទីតាំងសម្លាប់មនុស្ស និងឃុំខ្លួនពាក់ព័ន្ធនានា[9]
- មន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្សភូមិចក្រី[10]
- ទីតាំងសម្លាប់មនុស្សព្រៃតារ៉ូត[11]
- ទីតាំងសម្លាប់មនុស្សវត្តចំការខ្នុរ[12]
- ការដ្ឋានទំនប់ត្រពាំងថ្ម[13]។

៥. នៅថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៧ នៅក្នុងសេចក្តីជូនដំណឹងអំពីចេតនាបន្ថែមទម្រង់នៃការទទួលខុសត្រូវ តាមវិធីដីកាបង្គាប់របស់តុលាការ និងការផ្អាកកិច្ចស៊ើបសួរបណ្តោះអាសន្ន[14] ខ្ញុំបានជូនដំណឹងភាគីទាំងអស់អំពីបំណងរបស់ខ្ញុំមិនស៊ើបអង្កេតថែមទៀតលើអង្គហេតុថែមទៀតទេ។

---

[6]សំណុំរឿង ០០៤ ឯកសារ D272/1 *ចម្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យចុះថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ២០១៥ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមពាក់ព័ន្ធនឹងវិសាលភាពនៃកិច្ចស៊ើបសួរលើអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុងតំបន់ ១ និងតំបន់ ៤* ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ("ដីកាសន្និដ្ឋានបន្ថែមទី ៤") កថាខណ្ឌ ៦។

[7]សំណុំរឿង ០០៤ ឯកសារ D1 *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ៣ របស់សហព្រះរាជអាជ្ញា* ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ("ដីកាសន្និដ្ឋានទី ៣") កថាខណ្ឌ ៧៤-៧៥។

[8]ដីកាសន្និដ្ឋានទី ៣ កថាខណ្ឌ ៧៩។

[9]ដីកាសន្និដ្ឋានទី ៣ កថាខណ្ឌ ៧៧។

[10]ដីកាសន្និដ្ឋានទី ៣ កថាខណ្ឌ ៧៦។

[11]ដីកាសន្និដ្ឋានទី ៣ កថាខណ្ឌ ៧៦។

[12]ដីកាសន្និដ្ឋានទី ៣ កថាខណ្ឌ ៧១។

[13]ដីកាសន្និដ្ឋានទី ៣ កថាខណ្ឌ ៧៨។

[14]សំណុំរឿង ០០៤ ឯកសារ D342 *សេចក្តីជូនដំណឹងអំពីចេតនាបន្ថែមទម្រង់នៃការទទួលខុសត្រូវ តាមវិធីដីកាបង្គាប់របស់តុលាការ និងការផ្អាកកិច្ចស៊ើបសួរបណ្តោះអាសន្ន* ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៧។

៦. នៅថ្ងៃទី ១ ខែ កុម្ភៈ ឆ្នាំ ២០១៧ ស.ព.អ បានដាក់ចម្លើយតប[15]។ យឹម ទិត្យ មិនបានដាក់មតិយោបល់ណាមួយឡើយ។

៧. នៅថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១៧ ខ្ញុំបានចេញសេចក្តីជូនដំណឹងអំពីការផ្អាកកិច្ចស៊ើបសួរលើអង្គហេតុពាក់ព័ន្ធនឹងទីតាំងឧក្រិដ្ឋកម្មចំនួន ៦ កន្លែង ដោយជូនដំណឹងភាគីទាំងអស់ថា ខ្ញុំនឹងមិនបន្តស៊ើបអង្កេតលើអង្គហេតុថែមទៀតដែលបានចោទនៅក្នុងដីកាសន្និដ្ឋានរបស់ ស.ព.អ ដែលជាបឋមបង្ហាញឲ្យឃើញថាអាចអនុវត្តវិធានផ្ទៃក្នុង ៦៦ *ស្ទួន*៖

ក) **ទីតាំងឧក្រិដ្ឋកម្មទី ៨**[16]- អន្លង់វិលប្រែង និងទីតាំងសម្លាប់មនុស្សពាក់ព័ន្ធ[17]

ខ) **ទីតាំងឧក្រិដ្ឋកម្មទី ១៤**-ការដ្ឋានភ្នំត្រដាក់ចិត្ត[18]

គ) **ទីតាំងឧក្រិដ្ឋកម្មទី ១៥**- ទីតាំងសម្លាប់មនុស្ស បន្ទាយអូរតាក្រី[19]

ឃ) **ទីតាំងឧក្រិដ្ឋកម្មទី ២៣**- មន្ទីរសន្តិសុខវត្តកណ្តាល[20]

ង) **ទីតាំងឧក្រិដ្ឋកម្មទី ២៤**- មន្ទីរសន្តិសុខវត្តបន្ទាយនាង[21]

ច) **ទីតាំងឧក្រិដ្ឋកម្មទី ២៥**-មន្ទីរសន្តិសុខវត្តធម្មយុត[22]។

[15]សំណុំរឿង ០០៤ ឯកសារ D342/1 *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសេចក្តីជូនដំណឹងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិអំពីចេតនាដាក់បន្ថែមទម្រង់នៃការទទួលខុសត្រូវ តាមវិធីដីកាបង្គាប់របស់តុលាការ និងអំពីការផ្អាកជាបណ្តោះអាសន្ន* ថ្ងៃទី ១ ខែ កុម្ភៈ ឆ្នាំ ២០១៧។

[16]លេខរៀងទីតាំងឧក្រិដ្ឋកម្មដែលប្រើនៅក្នុងឯកសារនេះគឺយោងលើលេខរៀងដែលប្រើនៅក្នុងសំណុំរឿង ០០៤ ឯកសារ D281 *កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង* ថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ ២០១៥។

[17]ដីកាសន្និដ្ឋានបន្ថែមទី ១ កថាខណ្ឌ ៧។

[18]ដីកាសន្និដ្ឋានបន្ថែមទី ១ កថាខណ្ឌ ៧។

[19]ដីកាសន្និដ្ឋានទី ៣ កថាខណ្ឌ ៦១។

[20]ដីកាសន្និដ្ឋានទី ៣ កថាខណ្ឌ ៦៥ និង ៦៦។

[21]ដីកាសន្និដ្ឋានទី ៣ កថាខណ្ឌ ៦៩។

[22]ដីកាសន្និដ្ឋានទី ៣ កថាខណ្ឌ ៦៣-៦៤។

01465665



## II. ពិភាក្សា

៨. វិធានផ្ទៃក្នុង ៦៦ *ស្ទួន* (២) ចែងថា មុនពេលកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួ ស.ច.ស ត្រូវជូនដំណឹងអំពីព័ត៌មានលម្អិតស្តីពីគោលបំណងនៃការកាត់បន្ថយទៅភាគីទាំងអស់ បន្ទាប់មក ភាគី នឹងមានពេល ១៥ ថ្ងៃដើម្បីដាក់សារណា។

៩. តាមសំអាងហេតុដូចបានបញ្ជាក់នៅក្នុងសេចក្តីជូនដំណឹងអំពីការផ្អាកកិច្ចស៊ើបសួរខាងលើ ខ្ញុំមានបំណងដកអង្គហេតុទី ៦ អង្គហេតុទី ១៣ អង្គហេតុទី ១៤ និងអង្គហេតុទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មទី ៨, ១៤, ១៥, ២៣, ២៤ និង ២៥ ចេញពីកិច្ចស៊ើបសួរ យោងតាមវិធានផ្ទៃក្នុង ៦៦ *ស្ទួន* នៅពេលដែលបិទកិច្ចស៊ើបសួរ។

១០. បន្ទាប់ពីដកអង្គហេតុទី ៦ អង្គហេតុទី ១៣ អង្គហេតុទី ១៤ និងអង្គហេតុទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មទី ៨, ១៤, ១៥, ២៣, ២៤ និង ២៥ នៅពេលដែលបិទកិច្ចស៊ើបសួរ អង្គហេតុដែលនៅសេសសល់នឹងតំណាងឱ្យវិសាលភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់ ស.ព.អ ផ្នែកភូមិសាស្ត្រ ពេលវេលា និងអង្គសេចក្តីទាក់ទងនឹងលក្ខណៈ និងទំហំនៃឧក្រិដ្ឋកម្ម ព្រមទាំងប្រភេទជនរងគ្រោះ។

១១. តាមវិធានផ្ទៃក្នុង ៦៦ *ស្ទួន* (៥) ភស្តុតាងពាក់ព័ន្ធនឹងអង្គហេតុដែលបានដកចេញ នៅតែអាចប្រើប្រាស់ជាមូលដ្ឋានបានឱ្យតែពាក់ព័ន្ធនឹងអង្គហេតុដែលនៅសេសសល់។

១២. ការដកចេញអង្គហេតុទី ៦ អង្គហេតុទី ១៣ អង្គហេតុទី ១៤ និងអង្គហេតុទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មទី ៨, ១៤, ១៥, ២៣, ២៤ និង ២៥ នឹងមិនប៉ះពាល់ដល់ឋានៈរបស់ដើមបណ្តឹងរដ្ឋប្បវេណី ឬសិទ្ធិរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងការចូលរួមកិច្ចស៊ើបសួរឡើយ។

**តាមសំអាងហេតុខាងលើ ខ្ញុំ៖**

១៣. **ជូនដំណឹង** ភាគីទាំងអស់ អំពីបំណងរបស់ខ្ញុំដកអង្គហេតុទី ៦ អង្គហេតុទី ១៣ អង្គហេតុទី ១៤ និងអង្គហេតុទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មទី ៨, ១៤, ១៥, ២៣, ២៤ និង ២៥ ចេញពីកិច្ចស៊ើបសួរ យោងតាមវិធានផ្ទៃក្នុង ៦៦ *ស្ទួន*។

១៤. **អញ្ជើញ** ភាគីទាំងអស់ ដាក់សារណា ក្នុងរយៈពេល ១៥ ថ្ងៃចាប់ពីថ្ងៃចេញសេចក្តីជូនដំណឹងនេះ។

១៥. **ជូនដំណឹង** ភាគីទាំងអស់ថា ខ្ញុំនៅតែទទួលពិនិត្យអង្គហេតុទាំងអស់ខាងលើ ហើយសេចក្តីជូនដំណឹងនេះ មិនប៉ះពាល់ដល់សមត្ថកិច្ចរបស់ខ្ញុំក្នុងការបើកកិច្ចស៊ើបសួរឡើងវិញលើអង្គហេតុទាំងនេះឡើយប្រសិនបើខ្ញុំសម្រេចថាមានមូលហេតុត្រូវធ្វើដូច្នេះ។

១៦. **បញ្ជាក់** ថា ការឆ្លើយតប និងសារណាតបទៅនឹងសារណារបស់ភាគីផ្សេងទៀតយោងតាមវិធានផ្ទៃក្នុង ៦៦ *ស្ទួន* (២) នឹងមិនទទួលយកឡើយ។

ភ្នំពេញ ថ្ងៃទី០៤ ខែឧសភា ឆ្នាំ ២០១៧

E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

**ចៅក្រម Michael Bohlander**

**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**

**International Co- Investigating Judge**

**Co-juge d'instruction International**